ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**
សំណុំរឿងព្រហ្មទណ្ឌលេខ ១១៣៩
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០
សំណុំរឿងស៊ើបសួរលេខ ១២៣៥
ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ៧២
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១
**សាលក្រមព្រហ្មទណ្ឌលេខ ២០"ឃ"/២៩៥**
**ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១**

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការនៅថ្ងៃពុធ ៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ២:០០ នាទីរសៀល នៅសាលសវនាការ ខ២ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១៣៩ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] ជាន ភេទប្រុស អាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] រតនា មានកូន០១នាក់ ឪពុកឈ្មោះ [redacted] ស៊ីប "រស់" ម្តាយឈ្មោះ [redacted] ហម "រស់" ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ។ (គេចខ្លួន)

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ០៤ ចខស/ឌ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១

ជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនឹងអាយុជនរងគ្រោះ** ប្រព្រឹត្តនៅប្រទេសថៃ កាលពីខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី៖** ឈ្មោះ [redacted] ស្រីឡាស់ ឬ [redacted] ឡុះ ភេទស្រី [illegible] បច្ចុប្បន្នភូមិស្វាយ ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ត្រូវជាម្តាយបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] [illegible] ភេទស្រី កើតថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៨ ។

លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ

លោកស្រី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងខែមីនា ឆ្នាំ២០២០ ឈ្មោះ [redacted] សុម៉ាលី ភេទស្រី កើតថ្ងៃទី៦ ខែមករា ឆ្នាំ២០០៨ ត្រូវជាកូនបង្កើតរបស់ឈ្មោះ [redacted] ជាន បានទៅរស់នៅជាមួយឪពុកបង្កើតដែលជាជនសង្ស័យនៅប្រទេសថៃ ហើយនៅព្រឹកមួយឈ្មោះ [redacted] ជាន បានផឹកស្រាស្រវឹងមិនបានចេញទៅធ្វើការនោះទេ ដោយនៅផ្ទះជាមួយកូនស្រី ហើយបានធ្វើសកម្មភាពចាប់រំលោភកូនស្រីបានសម្រេចចំនួន០២ដង រហូតដល់កូនមានផ្ទៃពោះបានវិលត្រឡប់មកកម្ពុជាវិញនិងបង្កើតបានកូនប្រុសម្នាក់ ។

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៩៩១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០
- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៧០ អ.យ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១
- បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦២ "ឥ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២១
- បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ២៧៤ ពស.ព្រជ(ក) ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] ជាន បានគេចខ្លួនគ្មានចម្លើយ ។
- ជនរងគ្រោះឈ្មោះ [redacted] សុម៉ាលី បានឆ្លើយថា៖ ខ្លួនមានឪពុកឈ្មោះ [redacted] ជាន និងម្ដាយឈ្មោះ [redacted] ស្រីឡាស់ ហើយឪពុកម្ដាយខ្លួនបែកបាក់គ្នាតាំងពីខ្លួននៅតូចៗអាយុ៧ឆ្នាំ ក្រោយមកឪពុកខ្លួនហៅខ្លួនមករស់នៅជាមួយគាត់ ខ្លួនសម្រេចចិត្តមករស់នៅខាងឪពុកដែលមានមុខរបរជាកម្មករសំណង់ ខ្លួនរស់នៅជាមួយឪពុកមកដល់ពេលកើតរឿងហេតុរយៈពេល៧ឆ្នាំ ។ ដំបូងខ្លួននៅជាមួយឪពុកបាន២ឆ្នាំ ឪពុកយកស្រីក្រោយ បន្ទាប់មកទៅធ្វើការសំណង់នៅប្រទេសថៃ រួចនាំខ្លួនទៅជាមួយមើលកូនរបស់ប្រពន្ធក្រោយរបស់គាត់ ខ្លួនទៅរស់នៅប្រទេសថៃប្រហែល៤ឆ្នាំ ។ នៅថ្ងៃកើតហេតុ ប្រហែលថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ វេលាថ្ងៃត្រង់ ឪពុករបស់ខ្លួនអត់បានទៅធ្វើការទេ នៅផ្ទះជាមួយខ្លួន និងប្អូនតូចម្នាក់ទៀតដេកលក់ ស្រីក្រោយរបស់គាត់ទៅធ្វើការអស់ ដំបូងឪពុកខ្លួនដៃម្ខាងមានកាន់កាំបិតវែងដូចដាវសាមូរ៉ៃ ដែលគាត់សំលៀងរាល់ថ្ងៃចូលមកជិតខ្លួន បានបបួលលួងលោមសុំខ្លួនរួមភេទជាមួយ តែខ្លួនមិនព្រមប្រឹងរត់ចេញពីក្នុងផ្ទះ តែត្រូវឪពុកខ្លួនបានចាប់ដៃខ្លួនជាប់ អត់ឱ្យរត់ចេញពីផ្ទះ គំរាមមិនឱ្យស្រែក បើហ៊ានស្រែកនឹងសម្លាប់ខ្លួនចោល រួចគាត់ទៅចាក់សោរទ្វារផ្ទះជាប់ ពីផ្ទះមាននៅជាប់ៗគ្នា តែអ្នកជិតខាងទៅធ្វើការងារស្ងាត់អស់ពេលនោះឪពុកខ្លួនមានស្លៀកតែខោលីអូ និងក្រមា បានមកចាប់ផ្ដួលខ្លួនទៅលើក្ដារផ្ទះ ដៃម្ខាងខ្ទប់មាត់ខ្លួន ម្ខាងទៀតដោះអាវស្រាតខោក្រៅក្នុងរបស់ខ្លួន[illegible] រួចគាត់ដោះក្រមារបស់គាត់ចេញពីខ្លួនរបស់គាត់នៅតែខោលីអូ បន្ទាប់មកដៃម្ខាងរបស់គាត់ចាប់ខ្ទប់មាត់ខ្លួន ឯដៃម្ខាងទៀតចាប់ប្រឡេចប្រដាប់ភេទរបស់គាត់ចេញពីខោគាត់រួចរុញបញ្ចូលមកក្នុងប្រដាប់ភេទរបស់ខ្លួន និងធ្វើ

សកម្មភាពរុញច្រានឡើងក្នុងប្រដាប់ភេទរបស់ខ្លួនរំលោភខ្លួនរហូតបានសម្រេច និងនៅថ្ងៃដដែលវេលាម៉ោង៣ល្ងាច ឪពុកខ្លួនបានចាប់ខ្លួនម្តងទៀតធ្វើសកម្មភាពដូចមុន រំលោភខ្លួនរហូតដល់បានសម្រេច ។ ក្រោយធ្វើសកម្មភាពរំលោភមកលើខ្លួនរួច ឪពុកខ្លួនគំរាមខ្លួនមិនឱ្យនិយាយប្រាប់គេ បើហ៊ាននិយាយនឹងយកខ្លួនទៅព្រៃកាប់ខ្លួនជាកង់ៗសម្លាប់ចោល។ ក្រោយមកខ្លួនមានផ្ទៃពោះបាន៣ខែម្តាយចុងខ្លួនឃើញពោះខ្លួនធំ ម្តាយចុងគាត់ឆ្ងល់បានពិនិត្យទឹកនោមខ្លួនលទ្ធផលឃើញមានកូន រួចនាំខ្លួនទៅផ្ទះមីងជិតខាងសួរនាំខ្លួនឱ្យប្រាប់រឿងហេតុកើតឡើងដល់គាត់ ហើយខ្លួនបានរៀបរាប់នូវសកម្មភាពប្រាប់ពួកគាត់ ទើបដឹងរឿងរ៉ាវ បន្ទាប់មកអ្នកជិតខាងបានប្តឹងទៅថៅកែថៃ រួចថៅកែថៃបានចាត់ចែងឱ្យខ្លួនរស់នៅផ្សេងបែកពីឪពុក ។ បានរយៈពេល២ខែ ថៅកែថៃបានបញ្ជូនខ្លួនឱ្យទៅធ្វើដំណើរជុំជាមួយឪពុក និងម្តាយចុង មកដល់ស្រុកខ្មែរវិញ ។ ខ្លួនបានសម្រាលកូនប្រុស៣ខែ ហើយខ្លួនបានមករស់នៅជាមួយម្តាយបង្កើតវិញ ។ ខ្លួនសំណូមពរឱ្យច្បាប់ចាប់ឪពុកដាក់ទោសឱ្យរាងចាល ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីឡាស់ បានឆ្លើយថា៖ ឈ្មោះ [redacted] សុម៉ាលី ជាកូនបង្កើតរបស់ខ្លួនហើយឈ្មោះ [redacted] ជាន ត្រូវជាប្តីរបស់ខ្លួន ។ ខ្លួននិងប្តីឈ្មោះ [redacted] ជាន មានកូន៣នាក់ជាមួយគ្នា និងបានបែកគ្នា រយៈពេល៧ឆ្នាំមកហើយ ពេលបែកគ្នាខ្លួនយកកូនទាំង៣នាក់មក មើលថែ ក្រោយមកប្តីទាមទារដណ្តើមយកកូនស្រីច្បងឈ្មោះ [redacted] សុម៉ាលី កើតថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៨ ។ ក្រោយពីកូនទៅរស់នៅខាងប្តីមក ខ្លួនមិនដែលដឹងឮដំណឹងសុខទុក្ខកូនទេ ។ ក្រោយពេលកើតរឿងហេតុរួច នៅចុងឆ្នាំ២០២០នេះ ខាងអង្គការផ្តល់ព័ត៌មានមកខ្លួនថាប្តីខ្លួនចាប់រំលោភកូនខ្លួនឯងរហូតមានផ្ទៃពោះសម្រាលបាន កូនប្រុសបាន៣ខែហើយ ក្រោយពីបានដឹងដំណឹងនេះខ្លួនមកជួយកូនឈ្មោះ [redacted] សុម៉ាលី នៅកន្លែងអង្គការនៅ កំពង់ក្តី ទើបកូនរៀបរាប់រឿងហេតុកើតឡើងប្រាប់ធ្វើឱ្យខ្លួនឈឺចាប់ជាខ្លាំងមិនអាចកាត់ថ្លៃបាន ដែលប្តីជាសត្វតិរច្ឆានធ្វើបាបកូនបង្កើតខ្លួនឯង ។

**សេចក្តីសន្និដ្ឋានរបស់ភាគីបន្ទាប់ពីបិទការពិភាក្សាដេញដោល**
**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ**

- លោកស្រី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយឆ្លងកាត់សវនាការមកឃើញថា កូនក្តីខ្លួនត្រូវបានចោទប្រកាន់ ក្រោមអង្គហេតុ កាលពីខែមីនា ឆ្នាំ២០២០ ជនជាប់ចោទបានចាប់រំលោភជនរងគ្រោះ ដែលត្រូវជាកូនបង្កើតរបស់ខ្លួនឈ្មោះ [redacted] សុម៉ាលី ។ បន្ទាប់ពីបានរំលោភមកជនរងគ្រោះ ក៏មានផ្ទៃពោះហើយ បច្ចុប្បន្នបានសម្រាលកូនប្រុសម្នាក់ដែលកើតចេញពីការរំលោភនេះ ។ តាមអង្គហេតុនេះ ឃើញថាភស្តុតាងក្នុងការបញ្ជាក់ទៅលើអង្គហេតុនេះ គឺមានតែចម្លើយជនរងគ្រោះ តែម្នាក់គត់និងឯកសារពិនិត្យផ្ទៃពោះ ដែលឆ្លើយដាក់បន្ទុកទៅលើជនជាប់ចោទ ក្រៅពីចម្លើយទាំងនេះគ្មានភស្តុតាងអ្វីផ្សេងទេ ។ មួយវិញទៀត ជនជាប់ចោទគឺជាកម្មករស៊ីឈ្នួលនៅថៃរហូតមក តាំងពីមុនពេលកើតហេតុ ក្រោយកើតហេតុក៏បានជូនជនរងគ្រោះ ត្រឡប់មកស្រុកកំណើតវិញដែរ ហើយជនជាប់ចោទមិនអាចចូលឆ្លើយដោះសារក្នុងរឿងនេះៗក៏មិនបញ្ជាក់ថាជនជាប់ចោទរត់គេចខ្លួននោះទេ។ ខ្លួនគិតថាប្រហែលជាជនជាប់ចោទពេលនេះមិនដឹងខ្លួនត្រូវបានចោទប្រកាន់ ក្នុងរឿងរំលោភសេពសន្ថវៈនេះផងទេ ។ ជាមួយគ្នានេះ ក្នុងរឿងនេះក៏មានមូលដ្ឋានក្នុងការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ

លាស់ផងដែរតាមរយៈការយក DNA របស់កូនជនរងគ្រោះ ដែលកំណត់ថាកើតចេញពីការរំលោភរបស់ជនជាប់ចោទនោះទៅប្រៀបធៀប DNAរបស់កូនដទៃផ្សេងទៀតរបស់ជនជាប់ចោទណាម្នាក់ដើម្បីកំណត់ថាកូននោះពិតជាកូនដែលកើតចេញមកពីអំពើរបស់ជនជាប់ចោទពិតដែរ ឬ ទេ? បញ្ហានេះខ្លួនមិនដឹងថា តើបច្ចុប្បន្នផ្នែកវិទ្យាសាស្ត្រ ក្នុងស្រុកយើងអាចធ្វើបាន ឬ ទេ តែបើធ្វើបានគួរតែធ្វើព្រោះការចោទប្រកាន់ និងផ្តន្ទាទោសលើជនណាម្នាក់ជាគោលការណ៍ច្បាប់ តម្រូវឲ្យមានភស្តុតាងគ្រប់គ្រាន់ទើបអាចចោទប្រកាន់ និងផ្តន្ទាទោសបាន ។ ខ្លួនសុំឲ្យតុលាការមុនធ្វើការសម្រេចសូមពិចារណាទៅលើភស្តុតាង និងសម្រេចតាមផ្លូវច្បាប់ ។

**មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានការពារ**

- លោកស្រី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានពិនិត្យទៅលើសំណុំរឿង ឃើញថាអំឡុងឆ្នាំ២០២០ កូនក្តីខ្លួនត្រូវបានឪពុកបង្កើតចាប់រំលោភរហូតដល់មានផ្ទៃពោះ ហើយជនជាប់ចោទពិតជាបានប្រើមធ្យោបាយគំរាមកំហែងថានឹងសម្លាប់កាប់ជនរងគ្រោះជាកង់ៗថែមទៀត ហើយអំពើនេះមានចែងក្នុងមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ម្យ៉ាងទៀតអំពើរបស់ជនជាប់ចោទមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ហើយជនរងគ្រោះគឺមានអាយុ១២ឆ្នាំ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ឯសំណងរដ្ឋប្បវេណីស្នើសុំឲ្យពិចារណាតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ចំពោះការស្នើសុំពិនិត្យ DNA របស់លោកស្រីមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទគឺមិនមានភាពត្រឹមត្រូវ តើកូនបង្កើតមានគំនិតចោទប្រកាន់ឪពុករបស់ខ្លួនបានដែរឬយ៉ាងណា តែដោយសារឪពុកនោះពិតជាមានចេតនាទុច្ចរិត និងបានធ្វើសកម្មភាពរំលោភកូនរបស់ខ្លួនបណ្តាលឲ្យមានផ្ទៃពោះប្រាកដមែន ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា**

- ក្រោយពីបានដេញដោលចប់សព្វគ្រប់ និងស្តាប់ចម្លើយរបស់ជនរងគ្រោះ ឃើញថាជនជាប់ចោទពិតជាបានធ្វើសកម្មភាពរំលោភទៅលើជនរងគ្រោះដែលជាកូនបង្កើតរបស់ខ្លួនបណ្តាលឲ្យមានផ្ទៃពោះប្រាកដមែន ដូច្នេះសុំតំកល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៧០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

**សំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណី**

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីឡាស់ បានសំណូមពរថា៖ ខ្លួនប្តឹងសុំទាមទារសំណងជំងឺចិត្ត ចំនួន ៨០.០០០.០០០(ប៉ែតសិបលាន)រៀល ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ
ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

- កាលពីអំឡុងខែមីនា ឆ្នាំ២០២០ ឈ្មោះ [redacted] ជាន ជាឪពុកបង្កើតបានធ្វើសកម្មភាពចាប់រំលោភកូនស្រីបង្កើតឈ្មោះ [redacted] សុម៉ាលី ភេទស្រី អាយុ១២ឆ្នាំ បានសម្រេចចំនួន០២ដង នៅប្រទេសថៃ រហូតដល់មានផ្ទៃពោះចំនួន៥ខែហើយ ។

- តាមចម្លើយរបស់ជនរងគ្រោះ និងពិនិត្យភស្តុតាង មានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុភស្តុតាងពាក់ព័ន្ធអាចបញ្ជាក់អោយឃើញថាពិតជាមានករណី រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនិងអាយុជនរងគ្រោះ ប្រព្រឹត្តនៅប្រទេសថៃ កាលពីខែមីនា ឆ្នាំ២០២០ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ មាឃ ជាន ប្រាកដមែន ។

- តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦២ "អ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប បានសម្រេចបញ្ជូនឈ្មោះ មាឃ ជាន ទៅជំនុំជម្រះពីបទ៖ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនិងអាយុជនរងគ្រោះ ប្រព្រឹត្តនៅប្រទេសថៃ កាលពីខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

- អំពើរបស់ជនជាប់ចោទ មានចេតនាទុច្ចរិត និងមានកាយសម្បទាគ្រប់គ្រាន់ ស្ថិតក្នុងវ័យដែលអាចដឹងខុសត្រូវបាន ហើយរាល់អំពើរបស់ជនជាប់ចោទសុទ្ធតែឆ្លងកាត់នូវការពិចារណាជាមុន ហើយអំពើប្រព្រឹត្តនេះគឺបង្កអោយមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសខុសនឹងច្បាប់ព្រហ្មទណ្ឌដែលចូលជាធរមាន ។

- មេធាវីការពារសិទ្ធិឲ្យជនជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីខ្លួនត្រូវបានចោទប្រកាន់ក្រោមអង្គហេតុ កាលពីខែមីនា ឆ្នាំ២០២០ ជនជាប់ចោទបានចាប់រំលោភជនរងគ្រោះដែលត្រូវជាកូនបង្កើតរបស់ខ្លួនឈ្មោះ [redacted] សុម៉ាលី ។ បន្ទាប់ពីបានរំលោភមកជនរងគ្រោះ ក៏មានផ្ទៃពោះហើយបច្ចុប្បន្នបានសម្រាលកូនប្រុសម្នាក់ដែលកើតចេញពីការរំលោភនេះ ។ តាមអង្គហេតុនេះ ឃើញថាភស្តុតាងក្នុងការបញ្ជាក់ទៅលើអង្គហេតុនេះ គឺមានតែចម្លើយជនរងគ្រោះ តែម្នាក់គត់និងឯកសារពិនិត្យផ្ទៃពោះ ដែលធ្វើយោគបន្ទុកទៅលើជនជាប់ចោទ ក្រៅពីចម្លើយទាំងនេះគ្មានភស្តុតាងអ្វីផ្សេងទេ ។ មួយវិញទៀត ជនជាប់ចោទគឺជាកម្មករស៊ីឈ្នួលនៅថៃរហូតមក តាំងពីមុនពេលកើតហេតុ ក្រោយកើតហេតុក៏បានជូនជនរងគ្រោះ ត្រឡប់មកស្រុកកំណើតវិញដែរ ហើយជនជាប់ចោទមិនអាចចូលឆ្លើយដោះសារក្នុងរឿងនេះៗក៏មិនបញ្ជាក់បានថាជនជាប់ចោទរត់គេចខ្លួននោះទេ។ ខ្លួនគិតថាប្រហែលជាជនជាប់ចោទពេលនេះមិនដឹងខ្លួនត្រូវបានចោទប្រកាន់ ក្នុងរឿងរំលោភសេពសន្ថវៈនេះផងទេ ។ ជាមួយគ្នានេះ ក្នុងរឿងនេះក៏មានមូលដ្ឋានក្នុងការស៊ើបអង្កេតឲ្យកាន់តែច្បាស់លាស់ផងដែរតាមរយៈការយក DNA របស់កូនជនរងគ្រោះ ដែលកំណត់ថាកើតចេញពីការរំលោភរបស់ជនជាប់ចោទនោះ ទៅប្រៀបធៀប DNA របស់កូនដទៃផ្សេងទៀតរបស់ជនជាប់ចោទណាម្នាក់ដើម្បីកំណត់ថាតើកូននោះពិតជាកូនដែលកើតចេញមកពីអំពើរបស់ជនជាប់ចោទពិតដែរ ឬ ទេ? បញ្ហានេះខ្លួនមិនដឹងថា តើបច្ចេកវិទ្យាវិទ្យាសាស្ត្រក្នុងស្រុកយើងអាចធ្វើបាន ឬ ទេ តែបើធ្វើបានគួរតែធ្វើព្រោះការចោទប្រកាន់ និងផ្តន្ទាទោសលើជនណាម្នាក់ជា

គោលការណ៍ច្បាប់តម្រូវឱ្យមានភស្តុតាងគ្រប់គ្រាន់ទើបអាចចោទប្រកាន់និងផ្តន្ទាទោសបាន ។ ខ្លួនសុំឱ្យតុលាការមុនធ្វើការសម្រេចសូមពិចារណាទៅលើភស្តុតាង និង សម្រេចតាមផ្លូវច្បាប់ ។ ឃើញថា ភស្តុតាងជាបន្ទុកគឺការអះអាងរបស់ជនរងគ្រោះដែលត្រូវជាកូនបង្កើតរបស់ជនជាប់ចោទ និងការពិនិត្យការរំលោភផ្លូវភេទ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ របស់មន្ទីរសុខាភិបាលខេត្តសៀមរាប គឺមានស្នាមរហែកចាស់លើសន្ធះព្រហ្មចារីយ៍របស់ជនរងគ្រោះ ហើយជនរងគ្រោះមានគភ៌ ម្យ៉ាងទៀតជនរងគ្រោះទើបមានវ័យ១២ឆ្នាំ ដូច្នេះគប្បីតុលាការពិចារណានិងសម្រេចតាមច្បាប់ ។

- មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ឯសំណងរដ្ឋប្បវេណីសុំឱ្យពិចារណាតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ គប្បីតុលាការពិចារណានិងសម្រេចតាមច្បាប់ ។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ប្តឹងសុំតំកល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៧០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ទុកជាបានការដដែល ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

- មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះមាឃ ជាន ភេទប្រុស អាយុ៣៦ឆ្នាំ ពីបទ៖ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនិងអាយុជនរងគ្រោះ ប្រព្រឹត្តនៅប្រទេសថៃ កាលពីខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

- ជនជាប់ចោទឈ្មោះ [redacted] ជាន ភេទប្រុស អាយុ៣៦ឆ្នាំ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយជនជាប់ចោទបានគេចខ្លួន គប្បីអនុវត្តដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនលើជនជាប់ចោទ ស្របតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លន់ ស្រីឡាស់ បានទាមទារសំណងរដ្ឋប្បវេណីជាប្រាក់ចំនួន ៨០,០០០,០០០(ប៉ែតសិបលាន)រៀល គប្បីតុលាការពិចារណានិងសម្រេចតាមច្បាប់ ។

## ហេតុដូច្នេះ សម្រេច

១- ផ្តន្ទាទោសលើឈ្មោះ [redacted] ជាន ភេទប្រុស អាយុ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ ។

ពីបទ៖ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងនិងអាយុជនរងគ្រោះ ប្រព្រឹត្តនៅប្រទេសថៃ កាលពីខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឱ្យឈ្មោះ [redacted] ជាន សងសំណងរដ្ឋប្បវេណីចំនួន ៤០.០០០.០០០(សែសិបលាន)រៀល ឱ្យទៅឈ្មោះ [redacted] ស្រីឡាស់ ជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការទាមទារលើសពីនេះ ត្រូវអនុវត្តតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣- ចេញដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនលើឈ្មោះ [redacted] ជាន ភេទប្រុស អាយុ៣៦ឆ្នាំ ស្របតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីឡាស់ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ផាន និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ "ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់" ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| [redacted] | [redacted] | [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
[illegible] ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]